# សេចក្ដីថ្លែងការណ៍រួម

ដោយមើលឃើញថា ការបង្រួបបង្រួមកំលាំងនយោបាយប្រជាធិបតេយ្យពិតប្រាកដ ជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ ដែលអាចធ្វើឱ្យស្ថានការណ៍សេដ្ឋកិច្ច សង្គម និងនយោបាយនៅក្នុងប្រទេសកម្ពុជា នាពេលអនាគតមានភាពល្អប្រសើរឡើងវិញនោះ ថ្នាក់ដឹកនាំគណបក្ស សម រង្ស៊ី និងថ្នាក់ដឹកនាំគណបក្ស សិទ្ធិមនុស្ស បានព្រមព្រៀងគ្នាជាគោលការណ៍ចាប់ពីពេលនេះទៅ បង្កើត**ចលនានយោបាយប្រជាធិបតេយ្យ**មួយ ។

**ចលនានយោបាយប្រជាធិបតេយ្យ**នេះ គឺផ្ដល់ជូនប្រជាពលរដ្ឋខ្មែរយើងដែលចង់ឱ្យមាន**ការផ្លាស់ប្ដូរ** របៀបដឹកនាំដើម្បី **សេដ្ឋកិច្ច សង្គម** និង**នយោបាយ**ដ៏ល្អថ្មីមួយ និងដើម្បីអភិវឌ្ឍន៍ប្រទេសយើងឈានទៅការទទួលបាននូវយុត្តិធម៌សង្គម ភាពថ្លៃថ្នូរ ប្រជាធិបតេយ្យ សេរីភាព ឯករាជ្យ បូរណភាព និងអធិបតេយ្យភាពពិតប្រាកដ នាពេលអនាគតតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ នៅឆ្នាំ២០១២ និងការបោះឆ្នោតជាសកលជ្រើសតាំងតំណាងរាស្ត្រនាឆ្នាំ២០១៣ ខាងមុខនេះ ដោយមាន**បញ្ជីបេក្ខជនតែមួយ** ។

គណបក្ស សម រង្ស៊ី និងគណបក្ស សិទ្ធិមនុស្ស មានជំនឿយ៉ាងមុតមាំថា គំនិតផ្ដួចផ្ដើមបង្កើតចលនានយោបាយប្រជាធិបតេយ្យនេះ នឹងក្លាយជាកំលាំងចលករថ្មីសំរាប់ការលើកទឹកចិត្ត និងជួយជំរុញឆន្ទៈអ្នកប្រជាធិបតេយ្យក៏ដូចជាប្រជាពលរដ្ឋខ្មែរ ដែលទទូចចង់បានការរួបរួមនេះឱ្យកាន់តែមានសន្ទុះខ្លាំងក្លាថែមទៀត ក្នុងការតស៊ូនយោបាយដើម្បីបុព្វហេតុជាតិ ។

*ភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩*

Sam Rainsy

**សម រង្ស៊ី**

**ប្រធានគណបក្ស សម រង្ស៊ី**

**កឹម សុខា**

**ប្រធានគណបក្ស សិទ្ធិមនុស្ស**